**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិបណ្តុះបណ្តាល**

**National Training Board (NTB)**

# កំណត់ហេតុប្រជុំ

## គណៈកម្មការប្រតិបត្តិនៃគណៈកម្មាធិការជាតិបណ្តុះបណ្តាល (NTB)

ឆ្នាំពីរពាន់ប្រាំមួយ ខែកញ្ញា ថ្ងៃទីម្ភៃ វេលាម៉ោងប្រាំបួនព្រឹក នៅសាលប្រជុំបម្ភៃមួយ(B21) ជាន់ទី១ នៃទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំគណៈកម្មការប្រតិបត្តិ នៃគណៈកម្មាធិការជាតិបណ្តុះបណ្តាល National Training Board(NTB) ក្រោមអធិបតីភាព **ឯកឧត្តម សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការជាតិបណ្តុះបណ្តាល (NTB) ។

**<u>សមាសភាពចូលរួម</u>**:

- សមាជិកគណៈកម្មការប្រតិបត្តិនៃគណៈកម្មាធិការជាតិបណ្តុះបណ្តាល(NTB) ចំនួន ១០ រូប សុំច្បាប់ ចំនួន ០១ រូប
- លេខាធិការចំនួន ០៣ រូប
- ជំនាញការ ADB ចំនួន ០៣ រូប
- ធនាគារអភិវឌ្ឍន៍ជនបទ ចំនួន ០១ រូប
- មន្ត្រីជំនាញ ចំនួន ០៣ រូប
- មន្ត្រីរៀបចំកិច្ចប្រជុំ និងអ្នកសម្របសម្រួល ចំនួន ០៦ រូប

**<u>របៀបវារៈនៃអង្គប្រជុំ:</u>**

១-ប្រកាសបើកអង្គប្រជុំដោយ **ឯកឧត្តម សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មការប្រតិបត្តិ

២- របាយការណ៍សង្ខេបស្តីអំពីគំរោងអភិវឌ្ឍន៏វិស័យអប់រំទី២ (ESDP II) (ធ្វើរបាយការណ៏ដោយ ឯកឧត្តម ពេជ សោភ័ន)

៣-ពិភាក្សាអនុម័តសៀវភៅណែនាំ ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ នៃកម្មវិធីបណ្តុះបណ្តាលជំនាញតាមលិខិតបញ្ជាក់ Voucher Skills Training Program (VSTP) (ធ្វើរបាយការណ៏ដោយ លោក ហាំង តុលា)

៤-ពិភាក្សាអនុម័តថវិកាបណ្តុះបណ្តាលជំនាញនៃកម្មវិធីបណ្តុះបណ្តាលជំនាញតាមលិខិតបញ្ជាក់(VSTP) ប្រចាំឆ្នាំ២០០៦ សំរាប់ខេត្តបាត់ដំបង និងខេត្តកំពត (ធ្វើរបាយការណ៏ដោយ លោក តឹប អឿន)

៥-របាយការណ៏ស្តីអំពី មូលនិធិជាតិបណ្តុះបណ្តាល National Training Fund(NTF) និងមូលនិធិបង្កើតមុខរបរដោយខ្លួនឯង Self-Employment Generation Fund (SEGF) (ធ្វើរបាយការណ៏ដោយ ឯកឧត្តម ឡៅ ហ៊ីម)

៦-មូលនិធិបង្កើតមុខរបរដោយខ្លួនឯង(SEGF) ភ្ជាប់នឹងកម្មវិធីបណ្តុះបណ្តាលជំនាញតាមលិខិតបញ្ជាក់(VSTP) (ធ្វើរបាយការណ៏ដោយ លោកស្រី ទុង សុភាព)

៧- ផ្សេងៗ

**របៀបវារៈទី១:**

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជាប្រធានអង្គប្រជុំ បានថ្លែងអំណរគុណ និងស្វាគមន៍យ៉ាងកក់ក្តៅបំផុតចំពោះ សមាជិក សមាជិការ នៃអង្គប្រជុំដែលបានចូលរួមតាមការអញ្ជើញ។ ឯកឧត្តម ក៏បានជម្រាបបញ្ជាក់បន្ថែមផងដែរ ជូនអង្គប្រជុំទាំងមូលនៃគណៈកម្មាធិការជាតិបណ្តុះបណ្តាល(NTB) បានប្រជុំក្រុមប្រឹក្សានេះម្តងរួចមកហើយ គឺនៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០០៦ រហូតដល់ពេលនេះមានរយៈពេល០៦ខែ។ ថ្ងៃនេះយើងប្រជុំ គណៈកម្មការប្រតិបត្តិ និងអនុម័តលើមូលនិធិ ដើម្បីធ្វើយ៉ាងណាឱ្យគណៈកម្មាការជាតិបណ្តុះបណ្តាល(NTB) របស់យើងអាចឆ្លើយតបទៅនឹងសភាពការណ៍ពិតឱ្យបានល្អ និងសកម្ម។

**របៀបវារៈទី២:**

**ឯកឧត្តម ពេជ សោភ័ន** បានរាយការណ៍សង្ខេបជូននូវសាវតារឿងនៃគម្រោងអភិវឌ្ឍន៍វិស័យអប់រំទី២ (ESDP II) នេះ ។

ប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលបានទទួលឥទ្ធិពល ទាំងប្រព័ន្ធបារាំង សង្គមនិយម និងចុងក្រោយ គឺយើងទទួលនូវការប៉ះពាល់យ៉ាងច្រើនពីបណ្តាប្រទេសប្រើប្រាស់ភាសាអង់គ្លេស។

-ឆ្នាំ១៩៩៤ យើងបានការឧបត្ថម្ភពីADB ក្រោយពីបានសិក្សាស្រាវជ្រាវនូវបញ្ហាជាមូលដ្ឋានមួយចំនួន ដែលទាក់ទងនឹងប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ Technical Vocational Education and Training (TVET) ។

-ឆ្នាំ១៩៩៦ គម្រោង ADB ដែលបានជួយតាមរយៈ គម្រោងជំនាញជាមូលដ្ឋាន(Basic Skill Project) ដែលស្ថិតនៅក្រោមក្រសួងអប់រំ យុវជន និងកីឡា បានបន្តពីគម្រោងអង្គការពលកម្មអន្តរជាតិ (ILO) ដែលមានសកម្មភាពតាំងពីមុនពេលបោះឆ្នោតឆ្នាំ១៩៩៣ និងជាបច្ច័យមួយតម្រូវឱ្យមានការធ្វើការកែទម្រង់។ គម្រោងនេះមានគោលបំណងពីរ :

១-ធ្វើឱ្យប្រសើរឡើង នូវកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដល់ពលករបច្ចេកទេសជំនាញនៅស្រុកយើងមានគុណភាព។

២-សនិទានកម្មប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដើម្បីឱ្យឆ្លើយតបសេចក្តីត្រូវការទីផ្សារ ។

ពាក់ពន្ធ័នឹងរឿងពលករមួយចំនួនពិបាកនឹងរកការងារធ្វើពេលចេញពីសាលា យើងត្រូវរៀបចំកែលំអរប្រព័ន្ធនេះ ពេលនោះបានបង្កើតឡើងនូវគណៈកម្មាធិការជាតិបណ្តុះបណ្តាល(NTB)។

-ឆ្នាំ២០០២-២០០៧ គម្រោង ADB តាមរយៈ គំរោងអភិវឌ្ឍន៍វិស័យអប់រំទី១(ESDP I) មានគោលដៅគឺ :

១-បង្កើននូវសមភាព សិទ្ធិ ឱកាសការចូលរៀនរបស់កូនចៅយើង នៅក្នុងប្រព័ន្ធអប់រំមូលដ្ឋាន ឱ្យមានលក្ខណៈល្អជាងមុន ( ESDP I សំដៅភាគច្រើនគឺ ការសាងសង់សាលារៀននៅតាមបណ្តាលខេត្តផ្សេងៗ )

២-ការធ្វើវិមជ្ឈការ និងសហវិមជ្ឈការ ក្នុងការធ្វើផែនការ ការគ្រប់គ្រង និងការតាមដាន ត្រួតពិនិត្យ

៣-ធ្វើអន្តរាគមន៍លើវិស័យមួយចំនួនជាពិសេសក្នុង TVET

គម្រោងនេះ បានធ្វើវិមជ្ឈការរហូតដល់សាលារៀនតែម្តង និងបានបំផុសនូវគំនិតមួយ គឺធ្វើវិមជ្ឈការ ឬសហវិមជ្ឈការនៅសាលាត្រូវមានថវិកាឧបត្ថម្ភដោយខ្លួនឯង។ គម្រោង ESDP I ផ្នែក TVET ទទួលបាននូវថវិកាចំនួនតិចណាស់ ។ គម្រោងនេះមានរយៈពេល៥ឆ្នាំ គឺ ២០០៥-២០០៩ និងមានគោលបំណងធំ៧គឺ :

-កាត់បន្ថយភាពក្រីក្រ របស់ប្រជាជនយើង ដោយធ្វើឱ្យប្រសើរឡើង នូវឱកាសសម្រាប់ចូលរៀនក៏ដូចជាគុណភាព នៃការសិក្សានៅកម្រិតអប់រំមូលដ្ឋាន មធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ។ ទន្ទឹមនឹងនេះ ក៏បង្កលក្ខណៈឱ្យសិស្សចាកចេញពីសាលារៀនមានឱកាសបន្តការសិក្សា។

-ផែនការយុទ្ធសាស្ត្រក្នុងគម្រោងជំនាញជាមូលដ្ឋាន(Basic Skill Project) រហូតមកដល់ពេលនេះនៅតែមានតំលៃនៅឡើយទេ ព្រោះពាក់ព័ន្ធនឹងការកែទម្រង់ប្រព័ន្ធមួយដែលពីមុនផ្អែកលើលទ្ធភាពនៃការផ្គត់ផ្គង់ឱ្យទៅជាប្រព័ន្ធមួយផ្អែកលើតម្រូវការនៃទីផ្សារ

និងបានកសាងនូវកម្មវិធីដែលបណ្តុះបណ្តាលផ្អែកលើសមត្ថភាព Competency Based Training(CBT) ហើយកម្មវិធីនេះយើងបានរៀបចំសម្រាប់ ២កម្រិតគឺៈ កម្រិតវិញ្ញាបនប័ត្រ និង កម្រិតឌីប្លូម(Diploma) ។

យើងបានរៀបចំនូវក្របខណ្ឌមួយមានកំនត់អំពីស្តង់ដានៃជំនាញនីមួយៗ បានកសាងស្តង់ដាមុខរបរប្រហែលជាង៣០ និងរៀបចំធ្វើឱ្យបានសុក្រិតបន្ថែមទៀត ដើម្បីអាចដាក់ឆ្លង NTB នៅថ្ងៃណាមួយ។ ប្រសិនបើ NTB សម្រេច យើងអាចកែប្រែជាស្តង់ដាជាតិ ទោះជាសាលារដ្ឋក្តី ឯកជនក្តី អង្គការក្នុងស្រុក ឬក្រៅរដ្ឋាភិបាលក្តី ត្រូវតែអនុវត្តន៏តាមស្តង់ជាតិនេះ ។

លទ្ធផលទទួលបានតាំងពីគម្រោងជំនាញមូលដ្ឋាន Basic Skills Project(BSP) បានកែប្រែ TVET ពីការិយាល័យមួយនៅក្នុងនាយកដ្ឋានឧត្តមសិក្សា និងបច្ចេកទេស ទៅជានាយកដ្ឋានមួយ និងបន្ទាប់មកក៏បានប្រែក្លាយទៅជាអគ្គនាយកដ្ឋាន។ យើងបានធ្វើការកែលំអ និងតំឡើងឋានៈគ្រឹះស្ថាន TVET ក្នុងចំណោមសាលាទាំង៤នៅភ្នំពេញគឺ សាលាព្រះកុសុមៈ សាលាមធ្យមបច្ចេកទេសឧស្សាហកម្មឬស្សីកែវ វិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ និងវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស (វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេសមានភារកិច្ចជាចំបងក្នុងការបណ្តុះបណ្តាលគ្រូបច្ចេកទេសទូទាំងប្រទេស ក្រោយពីក្រសួងថ្មីបានបង្កើតឡើងក្នុងអាណត្តិទី៣នៃរាជរដ្ឋាភិបាលក៏បានអនុញ្ញាតឱ្យជ្រើសរើស ៣០០ នាក់ ក្នុង ១ ឆ្នាំ ) ។

មុនពេលបោះឆ្នោតឆ្នាំ ១៩៩៣ ILO បានជួយអន្តរាគមន៏លើខេត្តចំនួន ៧ ដើម្បីជួលអគារធ្វើជាសាលារៀន ហើយគម្រោងជំនាញមូលដ្ឋាន (BSP) បានសង់សាលានៅខេត្តចំនួន១៦ សំរាប់ការបណ្តុះបណ្តាលក្រៅប្រព័ន្ធមានរយៈពេលខ្លី និងបានសាងសង់សាលាឱ្យនារី WID បានចំនួន ៥ បន្ថែមទៀត ។

គម្រោងជំនាញជាមូលដ្ឋាន(BSP) បានជួយដល់TVETៈ ផ្នែក សាងសង់អាគារសិក្សា ទិញសំភារៈ និងការអភិវឌ្ឍន៏មន្ត្រី ។ ក្រោមគម្រោង BSPនេះ មូលនិធិជាតិបណ្តុះបណ្តាល National Training Fund(NTF) មាន ៣ ផ្នែក :

-ផ្តល់មូលនិធិសំរាប់ការបណ្តុះបណ្តាល

-ផ្តល់មូលនិធិកម្ចី ឱ្យសាលាឯកជនមានគំនិតច្នៃប្រឌិតថ្មីសម្រាប់បង្កើតអ្វីថ្មី

-ផ្តល់មូលនិធិឱ្យសិស្សខ្ចី បន្ទាប់ពីបានបញ្ចប់ការបណ្តុះបណ្តាលដើម្បីប្រកបមុខរបរដោយខ្លួនឯង

ជាកិច្ចបន្ត ឯកឧត្តម រដ្ឋលេខាធិការ បានសូមឱ្យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី និងជាប្រធានអង្គប្រជុំ ក៏ដូចជាអង្គប្រជុំទាំងមូលដើម្បីសម្រេចអនុម័តឱ្យបន្តលើលក្ខខណ្ឌថ្មី ពីព្រោះពេលមុន យើងយកការប្រាក់ទាប រីឯអ្នកអនុវត្តន៏គ្មានកំរៃ ហើយគម្រោងESDP គឺវាមានសារៈសំខាន់ណាស់សម្រាប់ការអភិវឌ្ឍន៏នៅក្នុង TVET ។

ក្នុងគម្រោង ESDP I បានសាងសង់មជ្ឈមណ្ឌលចំនួន០៤។ រីឯ ESDP II ជាគម្រោងដែលផ្តោតសំខាន់ គឺការសាងប្រព័ន្ធតម្រូវការមួយផ្អែកលើសហគមន៏។ ពាក់ព័ន្ធលើចំនុចទាំងនេះទើបកើតចេញជាសំនួរថា ហេតុអ្វីបានជាមានប្រព័ន្ធបណ្តុះបណ្តាលជំនាញតាមលិខិតបញ្ជាក់នេះកើតឡើង ? យើងបានសិក្សានឹងធ្វើការវិភាគលើទីផ្សារឃើញថា ពិតមែនតែវិស័យសេដ្ឋកិច្ចមានអត្រាកើនឡើងច្រើនផ្នែកឧស្សាហកម្ម បើប្រៀបធៀបនឹងផ្នែកខាងកសិកម្មក៏ដោយ។ ក៏ប៉ុន្តែចំនួនការងារនៅតែមានច្រើនផ្នែកកសិកម្ម ៧០% ដែលអ្នកប្រកបរបរកសិកម្មមានចំនួន ៨០% នៅឯជនបទ។ ដោយសារយើងមាន ថវិកាតិចត្រូវការដាក់ថវិកាណាជាអាទិភាពដល់កន្លែងណា ដែលចាំបាច់នោះគឺសហគមន៏តែម្តង។ ប្រព័ន្ធនេះផ្តល់ឱ្យមូលដ្ឋានជាអ្នកធ្វើផែនការបណ្តុះបណ្តាល និងឆ្លើយតបសមស្របទៅនឹងសភាពការណ៏ជាក់ស្តែងនៅទីនោះ។

គម្រោងនេះ ឃុំធ្វើផែនការបណ្តុះបណ្តាល(ដោយមានជំនួយពីមជ្ឈមណ្ឌលបណ្តុះបណ្តាលខេត្តជួយផ្ទាល់) ជាគំរោងសាកល្បងមួយមុនគេនៅស្រុកខ្មែរ ហើយយើងនឹងបង្រៀនខាងឃុំឱ្យពួកគេចេះធ្វើផែនការតាមលំដាប់លំដោយ។ ចំណែកឯរបៀបទំលាក់ថវិកាគឺយើងទំលាក់ទៅតាមខេត្តតែម្តង ហើយបានខេត្តទំលាក់ទៅតាមឃុំ និងរៀបចំធ្វើការបណ្តុះបណ្តាល។ ដូច្នេះជាគោលការណ៏ចំបងតាមបែប

ប្រព័ន្ធនេះ យើងមិនមែនឱ្យទៅជាលុយទេ ឱ្យជាលិខិតបញ្ជាក់ដែលបានកំណត់ទឹកប្រាក់ជាក់លាក់សំរាប់ការបណ្តុះបណ្តាល ទៅតាមនិតិវិធីរបស់គេ។ ដូច្នេះ ជាសរុប TVET យើង បានធ្វើអន្តរាគមន៍ ទៅតាមបណ្តាខេត្ត-ក្រុងដូចតទៅ:

-ជំហានដំបូងរបស់ ILO មាន៧ខេត្ត-ក្រុង ដែលមានការបណ្តុះបណ្តាលវិជ្ជាជីវៈ និងរៀបចំបន្ថែមទៀតតាមគំរោងជំនាញជាមូលដ្ឋានរហូតបាន១៦ ខេត្ត-ក្រុង

- ESDP I បានសាងសង់សាលាបន្តទៀត

-នៅសល់តែ ២ ខេត្ត ទៀតទេ ពុំទាន់បានសាងសង់មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត

**របៀបវារៈទី ៣ :**

លោក ហាំង តុលា បានរាយការណ៍ពីសៀវភៅ ណែនាំស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ នៃកម្មវិធីបណ្តុះបណ្តាលជំនាញតាមលិខិតបញ្ជាក់ ។

១. ការគ្រប់គ្រងហិរញ្ញវត្ថុនៃគម្រោងជំនួយក្រៅប្រទេស

២. ការគ្រប់គ្រងហិរញ្ញវត្ថុនៃកម្មវិធីបណ្តុះបណ្តាលជំនាញតាមលិខិតបញ្ជាក់

៣. គោលគំនិតក្នុងការគ្រប់គ្រងហិរញ្ញវត្ថុនៃកម្មវិធីបណ្តុះបណ្តាលជំនាញតាមលិខិតបញ្ជាក់

៤. រចនាសម្ព័ន្ធហិរញ្ញវត្ថុ:

៥. ការចរាចរ ឬលំហូរនៃសាច់ប្រាក់

**របៀបវារៈទី ៤ :**

លោក តឺប អឿន រាយការណ៍ជូនអង្គប្រជុំ សង្ខេបអំពីការបណ្តុះបណ្តាលជំនាញតាមលិខិតបញ្ជាក់ (VSTP) នៅក្នុងគំរោង ESDP II និងសុំសេចក្តីអនុម័តសម្រេចថវិកាពីអង្គប្រជុំ។ VSTP គឺជាការបណ្តុះបណ្តាលមួយ ដែលប្រើឯកសារជាលិខិតបញ្ជាក់ពីទឹកប្រាក់សំរាប់បណ្តុះបណ្តាលជំនាញ នៅក្នុងសហគមន៍ មានក្រុមប្រឹក្សាឃុំចូលរួមអនុវត្តន៍ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលខេត្តជាអ្នកសម្របសម្រួលលើការងារនេះ។ម្យ៉ាងទៀតយើងធ្វើការសាកល្បងនៅខេត្តចំនួន០៧ ដែលមាន ចំនួន២១០ឃុំ ក្នុងនោះបានអនុវត្តន៍លើខេត្តចំនួន ២ គឺខេត្តកំពត និងខេត្តបាត់ដំបង ក្នុងឆ្នាំ២០០៦ ចំនួន៦១ឃុំ និងនៅឆ្នាំ២០០៧ អនុវត្តន៍បន្តបន្ថែមលើខេត្តចំនួន៥ គឺខេត្តកំពង់ឆ្នាំង សៀមរាប ស្ទឹងត្រែង ស្វាយរៀង និងតាកែវ ដែលមានចំនួនសរុប១៤៩ឃុំទៀត។ មួយវិញទៀតក៏តំរូវឱ្យមានការបង្កើតគណៈកម្មាធិការខេត្ត-ក្រុងបណ្តុះបណ្តាល ដើម្បីជួយសម្របសម្រួល និងទទួលខុសត្រូវ។ ការបណ្តុះបណ្តាលតាមលិខិតបញ្ជាក់ ចែកចេញជា ៣ ប្រភេទ : ១-ការបណ្តុះបណ្តាលនៅតាមសហគមន៍ ២-ការបណ្តុះបណ្តាលតាមសហគ្រាស ៣-ការបណ្តុះបណ្តាលនៅតាមមជ្ឈមណ្ឌល ។

-ខេត្តបាត់ដំបង ចំនួនថវិកាសរុប គឺ$១៤៥,០០០ដុល្លារសហរដ្ឋអាមេរិក ក្នុងនោះមានថវិកា៨០%សំរាប់ធ្វើការបណ្តុះបណ្តាល ,ថវិកា១០% សំរាប់ការប្រតិបត្តិរបស់PTC និងថវិកា១០% ទៀតសំរាប់ធ្វើការត្រួតពិនិត្យ និងតាមដានលើការងាររបស់យើង នៅក្នុងនេះមានពីរគឺ NTB ៥% , ក្រុមប្រឹក្សាឃុំ និងគណៈកម្មាធិការខេត្ត-ក្រុងបណ្តុះបណ្តាល (PTB) ៥%ដែរ។ មជ្ឈមណ្ឌលខេត្តបាត់ដំបងបណ្តុះបណ្តាលសិក្ខាកាមចំនួន ៦,៤៣៨ នាក់។

-ខេត្តកំពតមានថវិកាសរុបគឺ$១៦០,០០០ដុល្លាអាមេរិច ក្នុងនោះមានថវិកា ៨០% សំរាប់ធ្វើការបណ្តុះបណ្តាល , ថវិកា១០% សំរាប់ការប្រតិបត្តិរបស់PTC និងថវិកា១០%ទៀតសំរាប់ ធ្វើការត្រួតពិនិត្យ និងតាមដានដូចខេត្តបាត់ដំបងដែរ។ មជ្ឈមណ្ឌលខេត្តកំពតបណ្តុះបណ្តាលសិក្ខាកាមចំនួន៧,១០៤នាក់។

ថវិកាសរុបតំរូវឆ្នាំ២០០៦ សំរាប់អនុវត្តន៍ទាំងពីរខេត្តគឺ ខេត្តបាត់ដំបង និងកំពតដោយប្រើប្រាស់អស់ ៣០៥,០០០ ដុល្លាសំរាប់ឆ្នាំ ២០០៦។ សិក្ខាកាមសរុបទាំងពីរខេត្តគឺ១៣,៥៤២ នាក់ ដូចគ្នាផងដែរថវិកាសរុប និងចំនួនសិស្សសំរាប់ឆ្នាំ២០០៧។

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី បានលើកយកបទពិសោធន៍លើគំរោង ២ មកជូនអង្គប្រជុំ :

ក-គំរោងទី១:ការផ្ទេរបច្ចេកវិទ្យាអប្សរានៅសៀមរាបលើការជួសជុលប្រាសាទ : មិនទាន់មានអ្នកជំនាញបច្ចេកទេសគ្មានលុយធ្វើ យើងបញ្ចូលស្ថាបត្យករបស់យើងដែលបានបណ្តុះបណ្តាលនៅស្រុកយើងឱ្យធ្វើជាមួយគេ មានការលំបាកច្រើនលើប្រាក់ខែ និងការងារ

ខ-គំរោងទី២ : សាលាការដ្ឋានបណ្តុះបណ្តាលវិជ្ជាជីវៈ ( Chantiers Ecoles de Formation Professionelle ( CEFP ) )

-បង្រៀនសិស្សឱ្យមានវិជ្ជាមួយ រើងរកស៊ីខ្លួនឯង

-បន្តឱ្យគេជួយ ១.២.៣.៤.៥ ឆ្នាំសិន ដើម្បីឱ្យកូនសិស្ស ក្លាយទៅជាអ្នកជំនាញ ទៅជាសិប្បករ

-បង្កើតជាសិប្បករអង្គរដើម្បីរកស៊ីដូចក្រុមហ៊ុន និងផ្តល់ការងារដល់សិស្សក៏ដូចជាប្រាក់ចំណូល

**<u>របៀបវារៈទី ៥ :</u>**

**ឯកឧត្តម ឡៅ ហ៊ុម** បានរាយការណ៍សង្ខេបជូនអង្គប្រជុំអំពីមូលនិធិជាតិបណ្តុះបណ្តាលដែលមានសមាសភាព ៣ :

-មូលនិធិផ្តល់ការបណ្តុះបណ្តាល Training Grant Fund (TGF) ផ្តល់ដល់ទាំង២៤ខេត្ត-ក្រុង តាមរយៈមជ្ឈមណ្ឌល អង្គការក្រៅរដ្ឋាភិបាល សមាគម សាលាឯកជន សំរាប់វគ្គខ្លីៗ ដល់ជនក្រីក្រ

-មូលនិធិផ្តល់លើការវិនិយោគ សំរាប់ជំនាញបង្កើតថ្មី Innovative Skills Investment and Loan Fund (ISILF)

-មូលនិធិបង្កើតមុខរបរដោយខ្លួនឯង Self-Employment Generation Fund (SEGF) or Micro Credit មូលនិធិឱ្យសិស្សខ្ចី បន្ទាប់ពីបានបញ្ចប់ការបណ្តុះបណ្តាលដើម្បីប្រកបមុខរបរដោយខ្លួនឯង

**<u>របៀបវារៈទី ៦ :</u>**

លោកស្រី ទុង សុភាព បានធ្វើការបកស្រាយអំពី មូលនិធិបង្កើតមុខរបរដោយខ្លួនឯង សំរាប់ផ្តល់ដល់សិស្សបានបញ្ចប់ការសិក្សាចាប់ពី$២០០-$២០០០ក្នុង១ក្រុម មានសមាជិកចាប់ពី៣-៥នាក់ អត្រាការប្រាក់១២%ក្នុង១ឆ្នាំ តែមានរយៈពេលអនុគ្រោះ៦ខែ ( មិនមានការប្រាក់ក្នុង៦ខែនេះ) ដូចនេះប្រើក្នុងរយៈពេល ១៨ ខែ មានន័យថា $0.៦៧ ក្នុងមួយខែ ដោយបានផ្តល់ជូនចំនួន ៥៦៥៣ នាក់ និងថវិកាចំនួន$១.២លានដុល្លាអាមេរិច ក្រុមការងារបានស្នើសុំភ្ជាប់ជាមួយVSTP។ ប្រព័ន្ធបណ្តុះបណ្តាលជំនាញតាមលិខិតបញ្ជាក់រៀបចំឡើងដើម្បីជួយកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ពេលបញ្ចប់គំរោងនោះយើងនឹងទទួលបានសិស្សចំនួន ១៣៩,៨៦០នាក់ និងមានទឹកប្រាក់សំរាប់ឃុំនីមួយៗចំនួន$៥០០០ដុល្លាអាមេរិច។ VSTPមិនបានផ្តល់ឥណទានដល់សិស្សបានរៀនចប់នោះទេ តែក្រុមជំនាញយើងខ្ញុំស្នើសុំផ្សារភ្ជាប់ជាមួយមូលនិធិបង្កើតមុខរបរដោយខ្លួនឯងដើម្បីឱ្យសិស្សខ្ចី។ ម្យ៉ាងទៀត ក្រុមជំនាញយើងខ្ញុំស្នើសុំតំឡើងការប្រាក់ពីមុនយក ១២ %ក្នុង១ឆ្នាំ តែឥឡូវសូមស្នើសុំ ១៨ % អាចខ្ចីបានពី $ ១០០ - $ ១០០០។

**គោលការណ៍ថ្មីនៃមូលនិធិបង្កើតមុខរបរដោយខ្លួនឯង( SEGF )មានដូចខាងក្រោម :**

| | |
|---|---|
| បុគ្គលិកលក្ខណៈនៃអ្នកខ្ចី | រៀនចប់ជំនាញបណ្តុះបណ្តាល និងជាអ្នកក្រីក្របំផុត ក្នុងចំណោមអ្នកក្រីក្ររៀនចប់កម្មវិធីបណ្តុះបណ្តាល តាមប្រព័ន្ធលិខិតបញ្ជាក់ ( **VSTP** ) |
| ចំនួនទឹកប្រាក់ឱ្យខ្ចីក្នុងមួយក្រុមៗ | $១០០ - $១០០០ |
| រយៈពេលប្រើប្រាស់ | ១៥ ខែ |
| រយៈពេលអនុគ្រោះ | ៣ ខែ ( គិតការប្រាក់ ) |
| អត្រាការប្រាក់ | ១.៥ % ក្នុង ១ខែ |
| ការបែងចែកប្រាក់ចំណូលដែលបានមកពីការប្រាក់<br>**-PTC**<br>**- NTB / Monitoring** | <br>៦% នៃការប្រាក់<br>៣% នៃការប្រាក់ |

| | |
|---|---|
| -SEGF | ៤% នៃការប្រាក់ |
| -ការប្រាក់សន្សំក្នុងធនាគារ | ៥% នៃការប្រាក់ |

ស្នើសុំអង្គប្រជុំពិនិត្យអនុម័ត និងសម្រេចដូចខាងលើនេះ ។

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** មានប្រសាសន៍ថាអ្នកធ្វើ Micro Credit លុះត្រាតែអ្នកនោះស្ទិតស្វាញណាស់ ។

**លោកស្រី នុខ សុភាព** បានបំភ្លឺថា កន្លងមកយើងមានមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ហើយយើងបានបញ្ចេញចំនួន ១៥ខេត្តនៅក្នុងគំរោងជំនាញជាមូលដ្ឋាន។ ពេលមុនយើងមានប្រាក់ឧបត្ថម្ភទៅខេត្ត ប៉ុន្តែក្រោយមកយើងខ្វះថវិកា ដូច្នេះក្រុមជំនាញស្នើសុំបង្កើនទឹកប្រាក់បន្ថែមទៀត ។

**ឯកឧត្តម ពេជ សោភ័ន** បានរាយការណ៍ជូនឯកឧត្តមប្រធានអង្គប្រជុំ និងអង្គប្រជុំជ្រាបថា :

-កន្លងមកយើងឱ្យតែអ្នកដែលទទួលការបណ្តុះបណ្តាល

-មុខសញ្ញាដែលយើងជ្រើសរើសមកបណ្តុះបណ្តាលគឺសុទ្ធតែអ្នកក្រីក្រ

-មុនចប់វគ្គយើងធ្វើការអប់រំបណ្តុះបណ្តាលពីការធ្វើផែនការសំរាប់ប្រកបមុខរបរដោយខ្លួនឯង

-ដាក់គំរោងស្នើសុំមកសាលា បានពិនិត្យត្រឹមត្រូវ និងមានការធានាពីប្រធានភូមិ មុននឹងឱ្យខ្ចី

**ឯកឧត្តម ស៊ុន គន្ធរ** បានមានយោបល់ :

-ដើម្បីចីរភាព និងគុណធម៌ ជ្រើសរើសអ្នកភូមិឱ្យចេះធ្វើការងារ និងផ្តល់ឥណទាន

-គាំទ្រការបង្កើនថវិកាបន្ថែម ព្រោះថវិកា $ ១.២ លានដុល្លាអាមេរិច គឺតិចតួចណាស់

-ត្រូវបង្រៀនមជ្ឈមណ្ឌលឱ្យគាត់ចេះគ្រប់គ្រងឥណទាន

-គួរតែបន្ថែមចលនាសហការណ៍ជាមួយ គណៈកម្មាធិការជាតិបណ្តុះបណ្តាល ហើយចាប់ផ្តើមធ្វើអ្វីដែលមានស្រាប់ និងរុញច្រាននូវអ្វីដែលមិនទាន់មាន

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** មានប្រសាសន៍ថា ដើម្បីឱ្យគំរោងមានជីវិត តើយើងត្រូវធ្វើដូចម្តេច ?

**ឯកឧត្តម ស៊ុន គន្ធរ** មានយោបល់ និងបទពិសោធន៍ :

-សម្របសម្រួលរវាងអ្នកវិនិយោគ និងការបណ្តុះបណ្តាល

-ត្រូវតំរង់ទិសសិស្សចេញពីសាលាមានការងារធ្វើ

-ធ្វើដូចម្តេចដើម្បីឱ្យគំរោងមូលនិធិបង្កើតមុខរបរដោយខ្លួនឯង វាអាចរស់បាន ដើរបានលុះត្រាតែ :

ក.យើងត្រូវរកដៃគូរបន្ថែម

ខ.យើងមានថវិកា $ ១.២ លានដុល្លាអាមេរិច គឺតិចតួចណាស់ ត្រូវរកទុនបន្ថែម

គ.បង្រៀនសហគមន៍ឱ្យចេះគ្រប់គ្រងនូវមុខរបរដោយខ្លួនឯង

**ឯកឧត្តម ពេជ សោភ័ន** បានបកស្រាយជូនឯកឧត្តមប្រធានអង្គប្រជុំ និងអង្គប្រជុំជ្រាបថា :

-គោលដៅមូលនិធិបង្កើតមុខរបរដោយខ្លួនឯង សិស្សដែលបានបញ្ចប់ទៅមានករងារធ្វើ

- គោលដៅមូលនិធិបង្កើតមុខរបរដោយខ្លួនឯង គាំទ្រនូវសកម្មភាពបណ្តុះបណ្តាល និងក្រុមមុខសញ្ញាសិស្សក្រីក្រ

-សិស្សរៀនចប់មានជំនាញ តែគ្មានថវិកា

-ស្នើសុំឱ្យឯកឧត្តមប្រធាន និងអង្គប្រជុំអនុម័តលើគំរោងផែនការដែលលោក តឹប អឿន បានលើកឡើងក្នុងឆ្នាំ ២០០៦នេះ ហើយផ្អែកលើគោលការណ៍ដែល ADB បានយល់ព្រម និងសៀវភៅណែនាំស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ នៃ VSTP។

-ស្នើសុំឱ្យឯកឧត្តមប្រធាន និងអង្គប្រជុំអនុម័តលើថវិកាត្រូវចំណាយក្នុងឆ្នាំ ២០០៦ និង ២០០៧ សំរាប់ ២ ខេត្ត ( ខេត្តកំពត និងបាត់ដំបង )

-ស្នើសុំឱ្យ ឯកឧត្តមប្រធាន និងអង្គប្រជុំ អនុម័តទៅលើការអនុញ្ញាតឱ្យប្រើប្រាស់ថវិកា ដែលមានតាំងពី BSP $១.២លានដុល្លាអាមេរិច សំរាប់ភ្ជាប់ជាមួយគំរោងថ្មី និងសូមអនុម័តលើការកែប្រែអត្រាការប្រាក់ ក៏ដូចជាការផ្តល់នូវថវិកាសំរាប់អង្គភាពអនុវត្តន៏ ។

**<u>ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី</u>** បានស្នើឱ្យជំនាញការមានយោបល់ និងផ្តល់ជាអនុសាសន៏នៅក្នុងគំរោងនេះ :

១- <u>Dr.Mathe</u>: ខ្ញុំគិតថាសាវតាមានលក្ខណៈ ខ្លាំង ពិបាក ត្រូវតែទាមទារឱ្យយើងត្រូវតែ កសាងនូវសមត្ថភាពទៅដល់ប្រជាជនកម្ពុជាដែលយើងធ្វើការជាមួយ ខ្ញុំគិតថាជំហានដំបូងត្រូវតែមានធនធានច្រើន និងសិក្សាឱ្យបានស៊ីជំរៅ ការផ្តោតសំខាន់នៃគំរោងគឺស្ថិតនៅលើសាលា រឺឯសមាសធាតុដទៃទៀត គឺយើងព្យាយាមជួយជនក្រីក្រ ដែលជាសិស្ស-និស្សិតគ្មានការងារធ្វើមានអាយុចាប់ពី ១៥-២១ឆ្នាំ។ ប៉ុន្តែយើងមិនត្រូវដាក់កំហិតទៅលើអាយុក្រោម២១ឆ្នាំចុះទេ ធ្វើយ៉ាងណាឱ្យមានលក្ខណៈអាចបត់បែនបាន។ គំរោងជំនាញជាមូលដ្ឋាន ដែលនៅមានមូលនិធិ$១.២លានដុល្លាអាមេរិចវាមិនមែនជាចំនួនច្រើននោះទេ ប៉ុន្តែយើងនឹងបន្ថែមនូវមូលនិធិកាន់តែច្រើនឡើងៗបន្តទៀត។ បញ្ហាសំខាន់របស់យើង គឺធ្វើឱ្យគំរោងមាននិរន្តរភាព ការផ្តល់នូវមូលនិធិបង្កើតមុខរបរដោយខ្លួនឯងនឹងធ្វើឱ្យគំរោងមាននិរន្តរភាព ជាជាងការផ្តល់នូវជំនួយឥតសំណងដល់ពួកគាត់ ។

២-<u>Dr. Pramod</u>: ការពិភាក្សា គឺផ្តោតលើឧស្សាហកម្ម ដែលខ្ញុំគិតថាវាមានលក្ខណៈជាក្រុមគោលដៅផលិតផលទាប គឺសំដៅលើប្រជាជនក្រីក្រ ភ្នាក់ងារផ្តល់ប្រាក់កម្ចីផ្សេងៗ បានធ្វើការយកកំរៃយ៉ាងខ្ពស់ ដោយសារពួកគេជ្រើសរើសក្រុមគោលដៅមានលក្ខណៈពិសេស ។

៣-<u>Mr. Harry</u>: យើងគួរចាប់ផ្តើមការពិភាក្សារបស់យើង អំពីការប្រាក់ សមាសភាពដទៃទៀត នៃគំរោងគឺការពង្រឹងសមត្ថភាពរបស់TVET ដូច្នេះផ្នែកមួយ នៃការទទួលខុសត្រូវរបស់យើង គឺត្រូវផ្តល់នូវសេវាកម្ម ដែលចង់សំដៅទៅលើការពង្រឹងនូវប្រព័ន្ធផ្ទៃក្នុងរបស់ TVET ។ ក្នុងផ្នែកសំខាន់មួយទៀត គឺយើងត្រូវធ្វើការបែងចែកនូវដំណើរ នៃការងារ ដើម្បីឱ្យសមស្របទៅនឹងការទាមទារធ្វើកំណែទំរង់របស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ផ្នែកសំខាន់មួយទៀតដែរ គឺថាភាពរលូននៃប្រព័ន្ធព័តិមាននៅក្នុងសាម៉ីអង្គភាពដែលវិស័យបច្ចេកវិទ្យាដើរតួយ៉ាងសំខាន់ ក្នុងដំណើរការណ៏គំរោងប្រកបដោយសុក្រិត្យភាព ។

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ឯកឧត្តម លោក លោកស្រី ជំនាញការជាតិ និងអន្តរជាតិ ដែលបានចូលរួមចំណែកផ្តល់យោបល់ ក៏ដូចជាបទពិសោធន៏ការងារកន្លងមក និងអនុសាសន៏ល្អៗ ដល់ដំណើរការណ៏នៃការអនុវត្តន៏គំរោងនេះ។ ក្នុងនោះដែរ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ក៏មានប្រសាសន៏ពាក់ព័ន្ធ នឹងអាយុត្រូវតែប្រែប្រួលតាមការងារ ។

អង្គប្រជុំ បានអនុម័តសំរេចរាល់ការស្នើសុំ និងឱ្យអនុវត្តគោលការណ៏ថ្មី និងប្រើប្រាស់ថវិកាដែលនៅសល់ $ ១.២ លានដុល្លាអាមេរិចបន្ត ។

អង្គប្រជុំបានចប់សព្វគ្រប់នៅវេលាម៉ោង ១៣ : ០០ នាថ្ងៃត្រង់ នាថ្ងៃ ខែ ឆ្នាំ ដដែល ក្រោមបរិយាកាសរីករាយ ស្និទ្ធស្នាលយោគយល់គ្នា និងយកចិត្តទុកដាក់ ។

លេខាកត់ត្រា

បានឃើញ និង ឯកភាព

ប្រធានអង្គប្រជុំ

**ហ៊ីង ស៊ីដេត**